**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ......០១៦/២២..........**ក.ប**/ស.ជ.៧.៣.ទក

# សេចក្តីជូនដំណឹង

## ស្តីពី

## ការរៀបចំទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ លើកទី៥ ឆ្នាំ២០២២ ក្រោមប្រធានបទ "TVET បង្កើនផលិតភាពការងារ និងភាពប្រកួតប្រជែងខ្ពស់"

យោងតាមអនុក្រឹត្យលេខ ១៥០ អនក្រ.បក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៧ និងសារាចរលេខ ០៤ សរ. ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០២២ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងរៀបចំទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ លើកទី៥ ឆ្នាំ២០២២ ក្រោមប្រធានបទ **"TVET បង្កើនផលិតភាពការងារ និងភាពប្រកួតប្រជែងខ្ពស់"** ដែលប្រព្រឹត្តទៅនៅថ្ងៃពុធ ១រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ នៅគ្រប់រាជធានី ខេត្ត ក្នុងគោលបំណងដើម្បីផ្សព្វផ្សាយពីសារៈសំខាន់នៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដល់សិស្ស និស្សិត យុវជន មាតាបិតា អាណាព្យាបាល សាធារណជន និងសហគ្រាស គ្រឹះស្ថាន ឧស្សាហកម្ម ក្រុមហ៊ុនឯកជន អង្គការជាតិ និងអន្តរជាតិ។ ក្រសួង នឹងរៀបចំផលិតឯកសារ រូបភាព និងវីដេអូផ្សេងៗ សម្រាប់ធ្វើការផ្សព្វផ្សាយនៅតាមស្ថានីយ៍វិទ្យុ ទូរទស្សន៍ និងបណ្តាញសង្គមនានា ព្រមទាំងមានការរៀបចំដាក់បង្ហាញស្នាដៃសិស្ស និស្សិតអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្នុងថ្ងៃទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ លើកទី៥ ឆ្នាំ២០២២ នេះ។ ក្នុងឱកាសនេះដែរ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏សូមអំពាវនាវដល់គ្រប់ភាគីពាក់ព័ន្ធ ជាពិសេសផ្នែកឯកជន ចូលរួមសហការ និងគាំទ្រដល់ការរៀបចំទិវាជាតិលើកទី៥ ឆ្នាំ២០២២ នេះ ឱ្យកាន់តែឧឡារិកអធិកអធមបន្ថែមទៀត។ *(បញ្ជាក់៖ សម្រាប់ទីតាំង និងពេលវេលាប្រារព្ធទិវាជាតិនេះ តាមរាជធានី ខេត្ត ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងជូនដំណឹងពេលក្រោយ)*

ព័ត៌មានលម្អិតសូមទំនាក់ទំនងមកកាន់នាយកដ្ឋានព័ត៌មានទីផ្សារការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានអាសយដ្ឋានផ្លូវសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឬតាមរយៈលេខទូរសព្ទ ០១៧ ៧៤៧ ៧៧៣/០៩៨ ៩៨៧ ៧៧៩/០៦១ ៧៧៧ ៦៣៧ ឬអ៊ីម៉ែល៖ pisey_ange@ymail.com/kimravuth@gmail.com។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សិស្ស និស្សិត យុវជន មាតាបិតា អាណាព្យាបាល សាធារណជន និងសហគ្រាស គ្រឹះស្ថាន ឧស្សាហកម្ម ក្រុមហ៊ុនឯកជន អង្គការជាតិ និងអន្តរជាតិ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ អង្គារ ៣ កើត ខែ ពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

ចម្លងជូន៖

- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
- គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរាជធានី ខេត្ត
- អង្គភាពពាក់ព័ន្ធ

  *"ដើម្បីផ្សព្វផ្សាយ"*
- ឯកសារ-កាលប្បវត្តិ

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩*